THE SCHOOL DISTRICT OF PHILADELPHIA

ការណែនាំសម្រាប់មាតាបិតា

# ការប្រឡង Keystone នៅរដ្ឋផិនស៊ីលវេនញ៉ា

## តើការប្រឡងឃីស្តូន (Keystone) ជាអ្វី?

ការប្រឡង Keystone គឺជាមូលដ្ឋានស្តង់ដារនៃការវាយតម្លៃសិស្សនៅពេលបញ្ចប់វគ្គសិក្សា បានរៀបចំឡើងដើម្បីវាយតម្លៃនៃការស្ទាត់ជំនាញក្នុងមុខវិជ្ជា ពិជគណិតកម្រិត១ (Algebra I) អក្សរសាស្ត្រ (Literature) និង ជីវវិទ្យា (Biology)។ ជាផ្នែកសំខាន់ៗជាច្រើន ចំពោះតម្រូវការនៃការបញ្ចប់ការសិក្សាពីវិទ្យាល័យទូទាំងរដ្ឋ នៅរដ្ឋផិនស៊ីលវេនញ៉ា។

## តើកូនខ្ញុំនឹងប្រឡង Keystone នៅពេលណា?

សាលារបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ាឲ្យសិស្សប្រឡង Keystone អំឡុងរដូវរងា (ខែមករា) និងអំឡុងរដូវផ្ការីក (ខែឧសភា)។ សិស្សដែលប្រឡង Keystone លើកទីមួយ តាមធម្មតាប្រឡងក្នុងអំឡុងរដូវផ្ការីក នៅពេលដែលពួកគេជិតបញ្ចប់វគ្គសិក្សា ពិជគណិតកម្រិត១ (Algebra 1) អង់គ្លេសកម្រិត២ (English 2) និង/ឬ ជីវវិទ្យា (Biology)។ ក្នុងអំឡុងរដូវរងា តាមធម្មតាទុកសម្រាប់សិស្សដែលត្រូវប្រឡង Keystone សាឡើងវិញ ប្រសិនបើពួកគេមិនបានពិន្ទុស្ទាត់ជំនាញ (proficient) នៅពេលប្រឡងលើកទីមួយ។ សិស្សក៏អាចប្រឡង Keystone សាឡើងវិញ ក្នុងអំឡុងរដូវផ្ការីក។ ប្រតិទិនសម្រាប់រយៈពេលនៃការប្រឡង Keystone អាចមើល ត្រង់នេះ។ លោកអ្នកក៏អាចមើល ប្រតិទិននៃការវាយតម្លៃសិស្សរបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា ព្រមទាំងប្រតិទិនសាលារបស់កូនលោកអ្នក សម្រាប់ថ្ងៃប្រឡង Keystone។

## តើគ្រូយកលទ្ធផលនៃការប្រឡង Keystone របស់កូនខ្ញុំទៅធ្វើអ្វី?

ពិន្ទុរបស់សិស្សម្នាក់ៗផ្តល់ទៅឲ្យតែសាលារបស់កូនលោកអ្នកតែប៉ុណ្ណោះ អាចប្រើដើម្បីជួយគ្រូក្នុងការធ្វើឲ្យដឹងពីភាពខ្លាំងពូកែ និងភាពអន់ខ្សោយរបស់កូនលោកអ្នក។ បន្ទាប់មកអនុញ្ញាតឱ្យគ្រូរៀបចំការបង្ហាត់បង្រៀនកូនរបស់លោកអ្នក ដើម្បីគាំទ្រល្អបំផុតដល់ការរីកចម្រើនរបស់ពួកគេ។ លើសពីនេះទៀត ដោយសារការប្រឡង Keystones ជាសមាសភាគមួយនៃតម្រូវការបញ្ចប់ការសិក្សាពីវិទ្យាល័យទូទាំងរដ្ឋនៃរដ្ឋផិនស៊ីលវេនញ៉ា សាលានឹងប្រើលទ្ធផលទាំងនេះដើម្បីឲ្យដឹងថាតើមុខវិជ្ជាអ្វីដែលសិស្សនឹងប្រឡងឡើងវិញ ដែលត្រូវការការបង្ហាត់បង្រៀនបន្ថែមដើម្បីឱ្យពួកគេរៀបចំខ្លួនឲ្យកាន់តែប្រសើរឡើងដើម្បីទទួលបានពិន្ទុស្ទាត់ជំនាញនៅពេលប្រឡងលើកទីពីររបស់ពួកគេ។ ពិន្ទុប្រឡង Keystone ក៏ផ្តល់ព័ត៌មានដល់សាលា និងក្រសួងអប់រំដែលគាំទ្រការកែលម្អ និងការរៀបចំផែនការពិភាក្សាពីកម្មវិធីសិក្សា និងការបង្ហាត់បង្រៀន ផងដែរ។

## តើសំណួរប្រភេទណាដែលសួរនៅក្នុងការប្រឡង Keystones?

សម្រាប់ការប្រឡង Keystones ទាំងបី សិស្សត្រូវឆ្លើយសំណួរតាមការជ្រើសរើសចម្លើយមួយពីចម្លើយជាច្រើន (multiple choice) និងតាមការសរសេរពន្យល់ ខុសៗគ្នាជាច្រើន។ ចម្លើយតាមការសរសេរពន្យល់ត្រូវផ្តល់តាមការសរសេរជាលាយលក្ខណ៍អក្សរ និងដាក់ពិន្ទុតាមប្រើវិធី rubric។ ដើម្បីជ្រាបព័ត៌មានបន្ថែមអំពីប្រធានបទនេះ សូមមើលឯកសារដែលគេរៀបចំសម្រាប់ការប្រឡង អក្សរសាស្ត្រ ពិជគណិតកម្រិត ១ និង ជីវវិទ្យា ។

## តើពិន្ទុប្រភេទណាដែលរាយការណ៍នៅលើការប្រឡង Keystones?

សម្រាប់មុខវិជ្ជាដែលត្រូវប្រឡងទាំងបី សិស្សទទួលពិន្ទុដែលឆ្លើយត្រូវ (raw score) ពិន្ទុតាមស្តង់ដារ (scale score) និងពិន្ទុតាមកម្រិតដែលធ្វើបាន (performance tier rating) [(ក្រោមកម្រិត ស្មើកម្រិត ស្ទាត់ជំនាញ ឬកំរិតខ្ពស់ (Below Basic, Basic, Proficient, or Advanced)] ដែលជាប់ទាក់ទងនឹងពិន្ទុតាមស្តង់ដារជាក់លាក់។ ពិន្ទុតាមស្តង់ដារទាក់ទងនឹងកម្រិតដែលធ្វើបាននីមួយៗ ខុសគ្នាទៅតាមមុខវិជ្ជា។ សម្រាប់ការបែងចែកកាន់តែស៊ីជម្រៅ លោកអ្នកអាចមើល តារាងនៃលំដាប់កម្រិតពិន្ទុតាមស្តង់ដារ របស់ក្រសួងអប់រំនៃរដ្ឋផិនស៊ីលវេនញ៉ា។

លើសពីនេះទៀត ក្រសួងអប់រំនៃរដ្ឋផិនស៊ីលវេនញ៉ា ផ្តល់ឲ្យសាលានូវរបាយការណ៍នៃលទ្ធផលប្រឡងរបស់សិស្សម្នាក់ៗតាមប្រធានបទ។ ការប្រឡង Keystone នីមួយៗមានពីរប្រធានបទ។

### តើមានន័យដូចម្តេចបើបានពិន្ទុ ក្រោមកម្រិត ស្មើកម្រិត ស្ទាត់ជំនាញ ឬកម្រិតខ្ពស់?

ក្រសួងអប់រំនៃរដ្ឋផិនស៊ីលវេនញ៉ា មាន ការពណ៌នាអំពីពិន្ទុតាមស្តង់ដារ សម្រាប់ ពិជគណិតកម្រិត១ អក្សរសាស្ត្រ និង ជីវវិទ្យា នៅក្នុងវិបសៃ របស់គេ។

សម្រាប់ការប្រឡង **Keystone អក្សរសាស្ត្រ** ប្រធានបទពីរគឺ (១) អក្សរសាស្ត្រប្រឌិត និង (២) អក្សរសាស្ត្រមិនប្រឌិត។
សម្រាប់ការប្រឡង **Keystone ពិជគណិតកម្រិត១** ប្រធានបទទាំងពីរគឺ (១) ការគិតលេខ និងសមីការលីនេអ៊ែរ និងវិសមភាព (២) មុខងារលីនេអ៊ែរ និងការរៀបចំទិន្នន័យ។
សម្រាប់ការប្រឡង **Keystone ជីវវិទ្យា** ប្រធានបទទាំងពីរគឺ (១) ដំណើរការកោ
សិកា និងកោសិកា និង (២) ការបន្ត និងឯកភាពនៃជីវិត។

## តើការប្រឡង Keystones កំណត់ម៉ោងដែរឬទេ?

ការប្រឡង Keystones មិនកំណត់ម៉ោងទេ ប៉ុន្តែសិស្សមិនអាចបញ្ចប់ប្រធានបទក្នុងរយៈពេលច្រើនថ្ងៃបានទេ។ ប្រសិនបើសិស្សចាប់ផ្តើមប្រធានបទនៅថ្ងៃច័ន្ទ ពួកគេមិនអាចបញ្ចប់ផ្នែកនោះនៅថ្ងៃអង្គារបានទេ។ ក្រសួងអប់រំនៃរដ្ឋផិនស៊ីលវេនញ៉ា ផ្តល់ការប៉ាន់ស្មានម៉ោងក្នុងការប្រឡង Keystone នីមួយៗ។ សម្រាប់ជីវវិទ្យា ប្រធានបទទាំងពីរចំណាយពេលប្រហែល ៧២ នាទី សម្រាប់ប្រធានបទនីមួយៗ។ សម្រាប់អក្សរសាស្ត្រ ប្រធានបទទាំងពីរចំណាយពេលប្រហែល ៧៣ នាទី សម្រាប់ប្រធានបទនីមួយៗ។ ហើយសម្រាប់ ពិជគណិត ១ ប្រធានបទទាំងពីរចំណាយពេលប្រហែល ៧៥ នាទី ដើម្បីបញ្ចប់ប្រធានបទនីមួយៗ។ ទោះជាយ៉ាងណាក៏ដោយ គេមិនតម្រូវឱ្យសិស្សបញ្ចប់ការប្រ  ឡងតាមកំណត់ពេលទាំងនោះទេ ហើយគេផ្តល់ពេលវេលាថែមទៀតតាមការចាំបាច់ដើម្បីបញ្ចប់ការប្រឡង។

## តើការប្រឡង Keystones ប៉ះពាល់ដល់ពិន្ទុរបស់កូនខ្ញុំដែរឬទេ?

ការប្រឡងនេះមិនប៉ះពាល់ដល់ពិន្ទុរបស់សិស្សទេ។ ទោះជាយ៉ាងណាក៏ដោយ ពួកគេមានវិធីសំខាន់ពីរ ចំពោះតម្រូវការនៃការបញ្ចប់ការសិក្សាពីវិទ្យាល័យទូទាំងរដ្ឋ នៅរដ្ឋផិនស៊ីលវេនញ៉ា។

## តើកូនខ្ញុំប្រឡង Keystones ដោយរបៀបណា?

ការប្រឡង Keystones តាមធម្មតាធ្វើឡើងតាមការប្រើខ្មៅដៃ និងក្រដាស។ ទោះជាដូច្នេះក៏ដោយ ក៏មានវិធីប្រឡងតាមអ៊ិនធ័រណែត ផងដែរ។ ដោយមិនគិតពីវិធីណាមួយដែលកូនរបស់លោកអ្នកត្រូវប្រឡង សិស្សទាំងអស់ត្រូវតែទៅប្រឡង Keystones នៅសាលារបស់ពួកគេផ្ទាល់។

## តើខ្ញុំអាចមើលលទ្ធផលនៃការប្រឡង Keystones នៅទីណា?

សាលាទទួលរបាយការណ៍របស់សិស្សម្នាក់ៗពីរច្បាប់ ពីរបីខែក្រោយពេលប្រឡងរួច។ លោកអ្នកអាចស្នើសុំរបាយការណ៍របស់សិស្សម្នាក់ៗមួយច្បាប់ពីសាលារបស់កូនលោកអ្នកបានដែរ។

លទ្ធផលក៏ចុះផ្សាយក្នុងគេហទំព័រសម្រាប់មាតាបិតា ក្រោមផ្នែកប្រឡងខ្នាតស្តង់ដារ (Standardized Test) នៃព័ត៌មានរបស់សិស្សផងដែរ។

## តើខ្ញុំអាចទាក់ទងទៅអ្នកណាបើខ្ញុំមានសំណួរថែមទៀតអំពីការប្រឡង Keystones?

ប្រសិនបើលោកអ្នកមានសំណួរថែមទៀតអំពីការប្រឡង Keystones យើងសូមឱ្យលោកអ្នកទាក់ទងទៅសាលារបស់កូនលោកអ្នក។ ព័ត៌មានសម្រាប់ទាក់ទងទៅសាលារបស់កូនលោកអ្នកអាចយកពីវិបសៃផ្ទុកព័ត៌មានសាលា ថ្មី របស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា។

## តើខ្ញុំអាចរកព័ត៌មានបន្ថែមអំពីការប្រឡង Keystones នៅទីណា?

ការិយាល័យវាយតម្លៃសិស្សរបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា៖
https://www.philasd.org/research/#assessmentsera

គេហទំព័រស្តីអំពី Keystone របស់ក្រសួងអប់រំនៃរដ្ឋផិនស៊ីលវេនញ៉ា៖
https://www.education.pa.gov/K-12/Assessment%20and%20Accountability/Keystones/Pages/default.aspx